# ព្រះរាជក្រម

នស/រកម/០១០៦/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គ លើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ខ-ត្រូវបញ្ជាក់អោយច្បាស់នូវឯកសារធ្វើដំណើរ ឬអត្តសញ្ញាណដែលចេញដោយមានគុណភាពដែលគេមិនងាយ បន្លំក្នុងការប្រើប្រាស់ និងមិនអាចធ្វើក្លែងក្លាយ ឬកែប្រែអោយខុសច្បាប់ ផលិតម្លង ឬចេញ និង

៦-ធានានូវបូរណភាព និងសុវត្ថិភាពនៃការចេញអោយប្រើនូវឯកសារធ្វើដំណើរ ឬអត្តសញ្ញាណ ឬក្នុងនាមរដ្ឋជាសមាជិក និងការទប់ស្កាត់ភាពមិនស្របច្បាប់របស់គេ ការធានា និងការប្រើប្រាស់ ។

## មាត្រា ១៣

## ធម្មានុញ្ញភាព និងសុពលភាពនៃឯកសារ

តាមសំណូមពរនៃរដ្ឋជាសមាជិកមួយ និងរដ្ឋជាសមាជិកផ្សេងទៀត និងយោងទៅតាមច្បាប់នៅក្នុងរដ្ឋរបស់ខ្លួនបញ្ជាក់ពេលវេលាអោយច្បាស់លាស់នៃធម្មានុញ្ញភាព និងសុពលភាពនៃឯកសារធ្វើដំណើរ ឬអត្តសញ្ញាណដែលបានចេញ ឬអះអាងអោយមានការប្រើប្រាស់នៅក្នុងនាមរបស់ខ្លួន និងបានសង្ស័យ ឬក៏កំពុងប្រើប្រាស់ក្នុងអំពើជួញដូរមនុស្ស ។

## IV.អវសានបញ្ញត្តិ

## មាត្រា ១៤

## ខសន្យារក្សាទុក (ខករម្មិតត្រូវដែននិរាករណ៍)

១-គ្មានអ្វីក្នុងពិធីសារនេះដែលនាំអោយប៉ះពាល់ដល់សិទ្ធ កាតព្វកិច្ច ការទទួលខុសត្រូវនៃបណ្តារដ្ឋ ឬបុគ្គល នៅក្រោមច្បាប់អន្តរជាតិនេះ រួមមានច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយជាពិសេសដែលអាចអនុវត្តបាន ក្នុងអនុសញ្ញាឆ្នាំ ១៩៥១ និងពិធីសារឆ្នាំ ១៩៦៧ ដែលទាក់ទងទៅនឹងឋានៈជាជនភៀសខ្លួន និងគោលការណ៍ច្បាស់លាស់ដូចមានចែងក្នុងនោះ ។

២-វិធានការដែលបានរំលាត់ទុកក្នុងពិធីសារនេះនឹងត្រូវបកស្រាយ និងស្នើសុំនៅក្នុងមធ្យោបាយមួយដែលមិនរើសអើង ចំពោះមនុស្សដែលមានប្រវត្តិថាពួកគេជាជនរងគ្រោះនៃការជួញដូរមនុស្សខុសច្បាប់ ការបកស្រាយ និងការស្នើសុំនៃវិធានការទាំងនោះ និងមានជាមួយគោលការណ៍នៃការទទួលស្គាល់ជាលក្ខណៈអន្តរជាតិមិនប្រកាន់ពូជសាសន៍ ។

## មាត្រា ១៥

## ដំណោះស្រាយវិវាទ

១-បណ្តារដ្ឋជាសមាជិកត្រូវខិតខំប្រឹងប្រែងក្នុងការដោះស្រាយវិវាទដែលទាក់ទងទៅនឹងការបកស្រាយ និងការស្នើសុំតាមរយៈការចរចារនៅក្នុងពិធីសារនេះ ។

២-រាល់វិវាទទាំងឡាយដែលកើតមានឡើងរវាងរដ្ឋជាសមាជិកដែលទាក់ទងទៅនឹងការបកស្រាយ និងការស្នើសុំនៃពិធីសារនេះដែលមិនអាចដោះស្រាយបានតាមរយៈការចរចារនៅក្នុងពេលវេលាដ៏សមហេតុផលមួយ តាមរយៈនៃការស្នើសុំនៃរដ្ឋមួយ ឬបណ្តារដ្ឋទាំងនោះត្រូវបានដាក់ស្នើទៅអាជ្ញាកណ្តាលប្រសិនបើរយៈពេល ៦ ខែ បន្ទាប់ពីថ្ងៃដែលបានដាក់សំណើទៅអាជ្ញាកណ្តាល បណ្តារដ្ឋជាសមាជិកទាំងនោះដែលមិនអាចនឹងយល់ព្រមតាមការចាត់ចែងរបស់អាជ្ញាកណ្តាលនោះ រដ្ឋណាមួយក្នុងចំណោមនេះអាចដាក់វិវាទនោះទៅតុលាការយុត្តិធម៌អន្តរជាតិ ដោយស្នើសុំអនុលោមតាមលក្ខណៈច្បាប់របស់តុលាការនោះ ។

៣-រដ្ឋជាសមាជិកនីមួយៗអាចនៅពេលដែលចុះហត្ថលេខាដល់សច្ចានុម័ត ការទទួល ឬការស្នើសុំ ឬដែលបានកំណត់ក្នុងពិធីសារនេះ ប្រកាសថាមិនអាចធ្វើការពិចារណាដោយខ្លួនឯងដែលមាននៅក្នុងវគ្គ ២នៃមាត្រានេះ ហើយបណ្តារដ្ឋជាសមាជិកដទៃទៀត និងមិនអាចយោងតាមវគ្គ ២ នៃមាត្រានេះដោយមានការគោរពទៅរដ្ឋជាសមាជិកមួយផ្សេងទៀតដែលបានធ្វើតាមការកំណត់លក្ខខ័ណ្ឌទាំងនេះ ។

៤-រដ្ឋជាសមាជិកណាមួយដែលបានធ្វើការកំណត់លក្ខខ័ណ្ឌ ដែលយោងតាមវគ្គ ៣ នៃមាត្រានេះ នឹងអាចដកនូវការកំណត់លក្ខខ័ណ្ឌនេះពេលណាក៏បានដោយធ្វើការបញ្ជាក់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ១៦

**ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការយល់ព្រមសេចក្តីស្នើសុំ និងការទទួលយក**

១-ពិធីសារនេះនឹងបើកចំហរទៅដល់បណ្តារដ្ឋទាំងអស់សម្រាប់ការចុះហត្ថលេខាពីថ្ងៃទី ១២-១៥ ខែ ១២ ឆ្នាំ ២០០០ នៅទីក្រុង ប៉ាលីម្ម ប្រទេសអ៊ីតាលី ហើយបន្ទាប់មកនៅឯទីស្នាក់ការអង្គការសហប្រជាជាតិនៅទីក្រុង ញូយក រហូតដល់ថ្ងៃទី ១២ ខែ ១២ ឆ្នាំ ២០០២ ។

២-នៅក្នុងពិធីសារនេះនឹងបើកចំហរផងដែរចំពោះការចុះហត្ថលេខាដោយ អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ អោយតែយ៉ាងហោយណាស់រដ្ឋជាសមាជិកមួយនៃអង្គការនេះបានចុះហត្ថលេខាលើពិធីសារនេះដោយយោងទៅតាមវគ្គ ១ នៃមាត្រានេះ ។

៣-ពិធីសារនេះគឺមានកម្មវត្ថុក្នុងការធ្វើសច្ចាប័ន ការយល់ព្រម និងការទទួលយកវិធានការនៃការធ្វើសច្ចាប័ន ការទទួលយក ឬការយល់ព្រមនឹងដាក់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ត្រូវចាត់វិធានការនៃការធ្វើសច្ចាប័នរបស់ខ្លួន ការទទួលយក ឬការយល់ព្រមយ៉ាងហោចណាស់សមាជិកនៃរដ្ឋមួយរបស់ខ្លួនត្រូវបានធ្វើដូច្នេះដែរ ។ ក្នុងវិធានការនៃការធ្វើសច្ចប័ននេះ ការទទួលយក ឬការយល់ព្រមអង្គការនោះនឹងត្រូវប្រកាសពីការខិតខំប្រឹងប្រែង តាមសមត្ថភាពរបស់ខ្លួនដោយមានការគោរពរាល់បែបបទដែលគ្របដណ្តប់ ក្នុងពិធីសារនេះ អង្គការនោះនឹងត្រូវជម្រាបផងដែរ ដល់អ្នកទទួលឯកសារនៃការពាក់ព័ន្ធនូវ ការបញ្ជាក់អះអាងនៃសមត្ថភាពខិតខំប្រឹងប្រែងរបស់ខ្លួន ។

៤-ពិធីសារនេះនឹងបើកចំហរក្នុងការទទួលយកដោយរដ្ឋណាមួយ ឬដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ណាមួយ ក្នុងនោះយ៉ាងហោចណាស់ រដ្ឋជាសមាជិកមួយ ដែលជាភាគីនៃពិធីសារនេះ ត្រូវចាត់វិធានការនៃការទទួលយកត្រូវបានដាក់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅពេលដែលមានការទទួលយល់ព្រមរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ត្រូវប្រកាសពីសមត្ថភាពរបស់ខ្លួន ដោយគោរពទៅលើបែបបទដែលគ្របដណ្តប់ពិធីសារនេះ ។ អង្គការតាំងនេះក៏ត្រូវជម្រាបផងដែរទៅអ្នកកាន់ឯកសារ ពាក់ព័ន្ធការបញ្ជាក់អះអាងណាមួយតៅតាមសមត្ថភាពរបស់ខ្លួន

## មាត្រា ១៧

## ការចូលជាធរមាន

១-ពិធីសារនេះនឹងចូលជាធរមានក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីដាក់អោយធ្វើសច្ចប័ន រយៈពេល ៤០ ថ្ងៃ ការទទួលយក ឬការយលព្រម ឬការស្នើសុំ លើកលែងតែថា វាមិនអាចចូលជាធរមាន មុនការចូលជាធរមាននៃអនុសញ្ញានេះ ក្នុងគោលបំណងនៃវគ្គនេះ រាល់វិធានការដែលបានដាក់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ នឹងមិនអាចទុកជាលក្ខណៈនៃការដាក់វិធានការបន្ថែមទាំងនោះដោយរដ្ឋជាសមាជិកនៃអង្គការនោះ ។

២-ចំពោះបណ្តារដ្ឋនីមួយៗ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ការធ្វើសច្ចាប័ន ការទទួល ឬការស្នើសុំ ឬក៏ការទទួលយល់ព្រមនៃពិធីសារនេះ បន្ទាប់ពីចាត់វិធានការរយៈពេល ៤០ ថ្ងៃនៃសកម្មភាពនេះ ។ ពិធីសារនេះនិងចូលជាធរមានរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ដោយរដ្ឋ ឬអង្គការនោះ ដេលពាក់ព័ន្ធទៅនឹងវិធានការ ឬនៅថ្ងៃដែលពិធីសារនេះចូលជាធរមានដែលភ្ជាប់ទៅនឹងវគ្គ ១ នៃពិធីសារនេះ ឬក្រោយពីនេះ ។

## មាត្រា ១៨

## ការធ្វើវិសោធនកម្ម

១-បន្ទាប់ពីផុតកំណត់រយៈពេល ៥ ឆ្នាំ ចាប់តាំងពីថ្ងៃចូលជាធរមាននៃពិធីសារនេះ រដ្ឋជាសមាជិកមួយនៃពិធីសារនេះអាចស្នើធ្វើវិសោធនកម្ម នឹងត្រូវដាក់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលនិងមាននៅលើទំនាក់ទំនងនៃការស្នើសុំធ្វើវិសោធនកម្ម ទៅបណ្តារដ្ឋដែលជាសមាជិក និងនៅសន្និបាតនៃភាគីទាំងអស់ចំពោះអនុសញ្ញាក្នុងគោលបំណងធ្វើការពិចារណា និងការសម្រេចចិត្តស្តីពីសំណើរនោះ ។ រដ្ឋជាសមាជិកនៃពិធីសារនេះនឹងធ្វើការប្រជុំគ្នានៅឯសន្និសីទ នៃបណ្តាភាគីទាំងអស់ ត្រូវខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីសម្រេចនូវការព្រមព្រៀងនៃការធ្វើវិសោធនកម្មនីមួយៗ ។ ប្រសិនបើរាល់កិច្ចខិតខំប្រឹងប្រែងក្នុងការព្រមព្រៀងមតិត្រូវបានពិភាក្សា ហើយមិនអាចឈានទៅដល់ការព្រមព្រៀង ការធ្វើវិសោធនកម្ម ត្រូវប្រើមធ្យោបាយចុងក្រោយបំផុត តម្រូវអោយមានការអនុម័តរបស់ខ្លួនក្នុងសម្លេងឆ្នោត ២/៣ នៃ

បណ្តារដ្ឋជាសមាជិកក្នុងពិធីសារនេះបង្ហាញអោយឃើញ ហើយនិងធ្វើការបោះឆ្នោត នៅក្នុងការធ្វើសន្និសីទនៃភាគីទាំងអស់ ។

២-អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ក្នុងបញ្ហាដែលស្ថិតនៅលើសមត្ថកិច្ចរបស់គេ នឹងត្រូវអនុវត្តនូវសិទ្ធក្នុងការបោះឆ្នោតទៅតាមមាត្រានេះជាមួយនឹងចំនួននៃការបោះឆ្នោតស្មើទៅនឹងចំនួននៃរដ្ឋសមាជិករបស់គេ ដែលស្ថិតនៅក្នុងភាគីនៃពិធីសារនេះ អង្គការទាំងនេះនឹងមិនអាចអនុវត្តនូវសិទ្ធិបោះឆ្នោតរបស់គេ ប្រសិនបើរដ្ឋជាសមាជិករបស់គេអនុវត្តផ្ទុយ ។

៣-ការធ្វើវិសោធនកម្មមួយត្រូវបានអនុម័តយោងទៅតាមវគ្គ ១ នៃមាត្រានេះ ក្នុងកម្មវត្ថុធ្វើសច្ចាប័ន ការយល់-ព្រមទទួល ការស្នើសុំដោយបណ្តារដ្ឋជាសមាជិក ។

៤-ការធ្វើវិសោធនកម្មមួយត្រូវបានអនុម័តយោងទៅតាមវគ្គ ១ នៃមាត្រានេះ នឹងចូលជាធរមានក្នុងការគោរពរដ្ឋជាសមាជិកមួយ រយៈពេល ៩០ ថ្ងៃ ដែលបានដាក់ពាក្យទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នៃការសុំធ្វើសច្ចាប័ន ការព្រមទទួលយក ឬការស្នើសុំនៃការធ្វើសោធនកម្មនេះ ។

៥-នៅពេលដែលការស្នើសុំធ្វើវិសោធនកម្មចូលជាធរមាន វានឹងត្រូវភ្ជាប់ជាមួយបណ្តារដ្ឋជាសមាជិកទាំងនោះដែលបានបង្ហាញការយល់ព្រមរបស់គេ ដែលភ្ជាប់ទៅនឹងច្បាប់នេះ ។ បណ្តារដ្ឋជាសមាជិកដទៃទៀតនឹងត្រូវជាប់នូវបទបញ្ញត្តិពិធីសារនេះ មុននឹងធ្វើវិសោធនកម្មផ្សេងៗដែលគេបានធ្វើសច្ចាប័ន បានទទួល ឬបានស្នើសុំ ។

## មាត្រា ១៩

## ការប្រកាសបដិសេធ

១-រដ្ឋជាសមាជិកមួយអាចប្រកាសបដិសេធនូវពិធីសារនេះ ដោយសរសេរបញ្ជាក់អះអាងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ការប្រកាសបដិសេធទាំងនេះនឹងមានប្រសិទ្ធិភាពរយៈពេល ១ ឆ្នាំ ក្រោយពីថ្ងៃទទួលនិងធ្វើការបញ្ជាក់ប្រាប់អោយដឹងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២-អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នឹងលែងជាភាគីនៃពិធីសារនេះ នៅពេលដែលរដ្ឋជាសមាជិករបស់ខ្លួនបានធ្វើការប្រកាសបដិសេធ ។

## មាត្រា ២០

## អ្នកទទួលបញ្ញើ និងការប្រើប្រាស់ភាសា

១-អគ្គលេខាធិការអង្គការសហប្រជាជាតិ គឺជាអ្នកផ្តើមអោយមានអ្នកកាន់បញ្ញើនៃពិធីសារនេះ

២-ច្បាប់ដើមនៃពិធីសារនេះ នៅក្នុងនោះមានភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង អេស្បាញ រុស្ស៊ី ។ អត្ថបទទាំងនោះមានតម្លៃដូចគ្នាទៅនឹងច្បាប់ដើម ដែលនឹងបានដាក់តំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ សាក្សីទាំងអស់ត្រូវចុះហត្ថលេខានៅខាងក្រោមដោយពេលលេញ ផ្តល់សិទ្ធិអំណាចដ៏ត្រឹមត្រូវដោយរដ្ឋាភិបាលរបស់ខ្លួន ត្រូវបានចុះហត្ថលេខាលើពិធីសារនេះ ។

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារស្តីពី ការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងសម័យប្រជុំលើកទី ៥៥ តាមសេចក្តីសម្រេចលេខ ៥៥/២៥ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០ នៅទីក្រុងញូវយ៉ក ហើយដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាចូលជាភាគី នាថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៦

នស.០១០៦.០២២ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**ហត្ថលេខា**

**អ៊ឹង កន្ថាផាវី**

លេខ: ៣៧៩.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

# ពិធីសារដើម្បីធ្វើការទប់ស្កាត់ បង្ក្រាប និង ការដាក់ទណ្ឌកម្ម លើការជួញដូរមនុស្សជាពិសេស លើស្ត្រី និង កុមារ និងការបំពេញបន្ថែមនូវអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង

អត្ថបទដែលដកស្រង់ពីច្បាប់ដើម ការថតចម្លងនេះត្រូវបាន បញ្ជាក់អះអាងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ នឹងត្រូវបានគេចេញផ្សាយនៅពេលក្រោយ

អង្គការសហប្រជាជាតិ
2000

# ពិធីសារដើម្បីធ្វើការទប់ស្កាត់ បង្ក្រាប និង ការដាក់ទណ្ឌកម្ម លើការជួញដូរមនុស្សជាពិសេស លើស្ត្រី និង កុមារ និងការបំពេញបន្ថែមនូវអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង

## បុព្វកថា

### បណ្តារដ្ឋជាសមាជិកពាក់ព័ន្ធនៅនឹងពិធីសារនេះ

ការប្រកាសនូវសកម្មភាពដ៏មានប្រសិទ្ធិភាពដើម្បីការពារ ហើយនិងប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្សជាពិ-សេសស្ត្រី និងកុមារ តម្រូវអោយមានការដោះស្រាយយ៉ាងទូលំទូលាយជាលក្ខណៈអន្តរជាតិ នៅតាមបណ្តាប្រទេសដើម ការឆ្លងកាត់ និងគោលដៅ ដោយរាប់បញ្ចូលទាំងបណ្តាវិធានការមួយចំនួនដើម្បីទប់ស្កាត់នូវអំពើជួញដូរមនុស្ស ការដាក់ទណ្ឌកម្មចំពោះអ្នកជួញដូរមនុស្ស ហើយនិងការពារជនរងគ្រោះពីការជួញដូរនេះ ដោយរាប់បញ្ចូលទាំងកិច្ចការពារសិទ្ធិរបស់ពួកគេដែលត្រូវបានទទួលស្គាល់ជា លក្ខណៈអន្តរជាតិ ។

ទទួលខុសត្រូវនូវការពិត បើទោះបីជាមានអត្ថិភាពផ្សេងៗគ្នានៃការគ្រប់គ្រង ថែរក្សា ឯកសារច្បាប់ជាលក្ខណៈអន្តរជាតិក៏ដោយ ក៏ត្រូវតែអនុវត្តនូវរាល់បណ្តាវិធានការដើម្បីប្រឆាំងលើការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលមិនទាន់មានឯកសារច្បាប់ជាទុទៅណាមួយដែលប្រឈមមុខរាល់ទិដ្ឋភាពនៃការជួញដូរមនុស្សនៅឡើយ ។

ទាក់ទិនទៅនឹងឯកសារច្បាប់ដែលមិនទាន់មានគ្រប់ជ្រុងជ្រោយ រាល់ជនទាំងឡាយណាដែលទទួលរងនូវអំពើជួញដូរ នឹងមិនត្រូវបានគេការពារអោយបានពេញលេញនៅឡើយ ។

ការរំលឹកឡើងវិញនូវសេចក្តីសម្រេចចិត្តរបស់សន្និបាតអង្គការសហប្រជាជាតិលេខ ៥៣/១១១ ចុះថ្ងៃទី ០៩ ខែ ១២ ឆ្នាំ ១៩៩៨ ដែលមហាសន្និបាតបានសម្រេច បង្កើតឡើងនូវអន្តររដ្ឋាភិបាលដោយមិនទាន់បានកំណត់នូវគណកម្មាធិការសិទ្ធិមនុស្សក្នុងគោលបំណងពិភាក្សាអោយបានល្អិតល្អន់ ទូលំទូលាយ នូវអនុសញ្ញាអន្តរជាតិប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង និងធ្វើការពិភាក្សាយ៉ាងល្អិតល្អន់រវាងគ្នាទៅវិញទៅមកជាអន្តរជាតិ ដើម្បីប្រឈមមុខទៅនឹងការជួញដូរស្ត្រី និងកុមារ ។

ជឿជាក់ថាការបំពេញបន្ថែមនូវអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង ជាមួយនិងឯកសារច្បាប់អន្តរជាតិក្នុងកិច្ចការពារ ទប់ស្កាត់ និងការដាក់ទណ្ឌកម្មដល់ការជួញដូរមនុស្សជាពិសេសលើស្ត្រី និងកុមារ និងមានផលប្រយោជន៍ក្នុងកិច្ចការពារ ព្រមទាំងប្រយុទ្ធប្រឆាំងទៅនឹងបទឧក្រិដ្ឋនោះ ។

បានព្រមព្រៀងគ្នាដូចខាងក្រោមនេះ:

## I-បទបញ្ញត្តិទូទៅ

### មាត្រា ១

ការទាក់ទិនជាមួយនិងអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង:

១-ការបំពេញបន្ថែមនូវអនុសញ្ញារបស់អង្គការសហប្រជាជាតិនៃពិធីសារនេះប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែននឹងត្រូវបានបកស្រាយរួមគ្នាជាមួយនឹងអនុសញ្ញា ។

២-រាល់បទបញ្ញត្តិនៃអនុសញ្ញានឹងមានប្រសិទ្ធិភាពដោយមានការផ្លាស់ប្តូរសមស្របទៅនឹងពិធីសារនេះលុះត្រាតែត្រូវបានគេចែងក្នុងនេះ ។

៣-រាល់បទល្មើសដែលគេបានបង្កើតឡើងដោយអនុលោមទៅតាមមាត្រា ៥ នៃពិធីសារនេះនឹងត្រូវបានគេចាត់ទុកថាជាបទល្មើសដែលបានបង្កើតឡើងដោយយោងទៅតាមអនុសញ្ញាខាងលើ ។

## មាត្រា ២
## គោលបំណងនៃសេចក្តីថ្លែងការ

គោលបំណងនៃពិធីសារនេះគឺ:

a-ការពារ និងប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្ស ជាពិសេសយកចិត្តទុកដាក់យ៉ាងសំខាន់ទៅលើស្ត្រី និងកុមារ ។

b-ការពារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ សំខាន់ត្រូវគោរពនូវសិទ្ធិរបស់ពួកគេអោយបានពេញ-លេញ ហើយនិង

c-ជម្រុញនូវកិច្ចសហប្រតិបត្តិការក្នុងចំណោមបណ្តារដ្ឋដែលជាសមាជិក ដើម្បីប្រឈមមុខទៅនឹងបញ្ហាទាំងនោះ

## មាត្រា ៣
## ការប្រើប្រាស់នូវពាក្យសំពី

សម្រាប់គោលបំណងនៃពិធីសារនេះ:

a-អំពើជួញដូរមនុស្ស គឺសំដៅទៅលើ ការជ្រើសរើសសមាជិកថ្មី ការដឹកជញ្ជូន ការផ្លាស់ប្តូរទីកន្លែងសំចត ឬក៏ទទួលអោយមនុស្សចូលដោយតាមមធ្យោបាយគំរាមកំហែង ឬការប្រើប្រាស់កម្លាំងឬក៏បែបបទនៃការបង្ខិតបង្ខំផ្សេងទៀតនៃការចាប់ជំរិត ការក្លែងបន្លំ ការឆបោក ការប្រើអំណាចដោយរំលោភបំពាន ឬក៏ការធ្វើអោយមានការឈឺចាប់ ឬក៏ការផ្តល់អោយ ឬក៏ទទួលនូវការចំណាយ ឬអត្ថប្រយោជន៍ ដើម្បីសម្រេចនូវការយល់ព្រមនៃមនុស្សណាម្នាក់ដែលមានការដែលមានការត្រួតពិនិត្យទៅលើមនុស្សម្នាក់ផ្សេងទៀតក្នុងគោលបំណងធ្វើអាជីវកម្ម ។ ការធ្វើអាជីវកម្មរាប់បញ្ចូលទាំងផ្នែកអប្បបរមានៃការធ្វើអាជីវកម្មលើស្រីពេស្យា និងស្ត្រីផ្សេងទៀត ឬបែបបទដទៃទៀតនៃការធ្វើអាជីវកម្មលើផ្លូវភេទដោយចាប់បង្ខំលើកម្លាំងពលកម្ម ឬសេវាកម្ម ទាសភាព ឬការប្រព្រឹត្តនោះប្រហាក់ប្រហែលទៅនឹងទាសភាព សេវតតិភាព ឬក៏ការផ្លាស់ប្តូរសរីរាង្គ ។

b-ការព្រមព្រៀងនៃជនរងគ្រោះដោយការជួញដូរមនុស្ស មានគោលបំណងធ្វើអាជីវកម្មដែលបានកំណត់ទុកក្នុងវាក្យខ័ណ្ឌ (a) នៃមាត្រានេះនឹងមិនទាក់ទងទៅនឹងមធ្យោបាយណាមួយដូចបានកំណត់ក្នុងវាក្យខ័ណ្ឌ (a) ដែលបានប្រើប្រាស់។

c-ការជ្រើសរើសសមាជិកថ្មី ការដឹកជញ្ជូន ការផ្លាស់ប្តូរទីកន្លែងសំចត ឬបង្កាន់ដៃក្មេងចូលក្នុងគោលបំណងធ្វើអាជីវកម្ម នឹងត្រូវបានគេចាត់ទុកថាជាការជួញដូរមនុស្ស ទោះបីជាករណីនេះមិនមានជាប់ពាក់ព័ន្ធចូលក្នុងមធ្យោបាយណាមួយដូចដែលបានកំណត់ទុកក្នុងវាក្យខ័ណ្ឌ (a) នៃមាត្រានេះ។

d-កុមារ គឺសំដៅទៅលើមនុស្សណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ ៕

## មាត្រា ៤
## វិសាលភាពនៃការស្នើសុំ

ពិធីសារនេះនឹងត្រូវអនុវត្ត លើកលែងតែមាត្រាដែលគ្មានចែងក្នុងនេះ ដើម្បីធ្វើការការពារ ការស៊ើបអង្កេត និងការកាត់ទោស នៃបទល្មើសទាំងឡាយដែលត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមមាត្រា ៥ នៃពិធីសារនេះដែលបទល្មើសទាំងអស់នោះគឺជាការឆ្លងដែនតាមធម្មតានិងជាប់ពាក់ព័ន្ធទៅនឹងក្រុមឧក្រិដ្ឋជនដែលបានចាត់តាំងឡើងមួយក៏ដូចជាការការពារនូវជនរងគ្រោះនៃបទល្មើសទាំងនេះ ។

## មាត្រា ៥
## បទឧក្រិដ្ឋតាមទម្រង់បទល្មើស

១-រដ្ឋនីមួយៗជាសមាជិកគួរតែអនុម័តច្បាប់នេះ និងមានវិធានការផ្សេងទៀតដែលចាំបាច់ ដើម្បីបង្កើតជាបទល្មើសឧក្រិដ្ឋដូចមានកំណត់ក្នុងមាត្រា ៣ នៃពិធីសារនេះ នៅពេលដែលត្រូវបានគេប្រព្រឹត្តដោយចេតនា ។

២-រដ្ឋនីមួយៗគួរតែអនុម័តនូវច្បាប់នេះ និងមានវិធានការផ្សេងទៀតដែលចាំបាច់ដើម្បីបង្កើតឡើងនូវបទល្មើសឧក្រិដ្ឋ។

a-ប្រធានបទចំពោះទស្សនៈជាមូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួនមានបំណងដើម្បីប្រព្រឹត្តនូវបទល្មើសដែលបានបង្កើត ឡើងដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

b-ការចូលរួមសមគំនិតក្នុងបទល្មើសមួយដែលបានបង្កើតឡើងដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ហើយនិង

c-ការចាត់តាំង ឬការចាត់ចែងនូវជនទាំងឡាយណាផ្សេងទៀតអោយប្រព្រឹត្តនូវបទល្មើសមួយដែលត្រូវបានគេបង្កើតឡើង ដោយយោងទៅតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

## II-ការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស

## មាត្រា ៦
## ការជួយសង្គ្រោះ និងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សខុសច្បាប់

១-នៅក្នុងករណីដែលសមស្រប ហើយនិងវិសាលភាពដែលអាចប្រព្រឹត្តិទៅបាននូវច្បាប់របស់ប្រទេសរៀងៗខ្លួន រដ្ឋនីមួយៗត្រូវការពារដាច់ដោយឡែកនិងអត្តសញ្ញាណរបស់ជនរងគ្រោះដោយអំពើជួញដូរ រាប់បញ្ចូលទាំងការទំនាក់ទំនងទៅវិញទៅមក តាមការបង្កើតឡើងនូវទម្រង់ការច្បាប់ដែលទាក់ទងទៅនឹងការជួញដូរដែលគួរអោយទុកចិត្តបាន ។

២-រដ្ឋនីមួយដែលជាសមាជិកត្រូវតែធានានូវច្បាប់ក្នុងប្រទេសរបស់ខ្លួន ឬក៏ប្រព័ន្ធរដ្ឋបាលដែលមានវិធានការថាផ្តល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅតាមករណីសមស្របដូចជា:

a-ពត៌មានស្តីពីការទាក់ទិនទៅនឹងតុលាការ និងទម្រង់ការផ្នែករដ្ឋបាល

b-ការជួយផ្តល់មធ្យោបាយ តាមទស្សនរបស់គេ ហើយនិងការទាក់ទងនោះនឹងត្រូវផ្តល់អោយព្រមទាំងពិនិត្យពិច័យទៅតាមដំណាក់កាលសមស្រប នូវទម្រង់បទឧក្រិដ្ឋប្រឆាំងទៅនឹងអ្នកប្រព្រឹត្តល្មើសក្នុងលក្ខណៈមួយដែលមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិនៃកិច្ចការពារ ។

៣-រដ្ឋនីមួយៗជាសមាជិកត្រូវពិចារណានូវការអនុវត្តរាល់វិធានការ ដើម្បីផ្តល់អោយដល់ជនរងគ្រោះដែលរួចផុតពីអំពើជួញដូរមនុស្ស ទាំងផ្លូវចិត្ត ផ្លូវកាយ និងសង្គមរស់នៅ រួមមានទាំងករណីសមស្របនៅក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល និងបណ្តាអង្គការពាក់ព័ន្ធ ហើយនិងសង្គមស៊ីវិលផ្សេងទៀត និងជាពិសេសបទបញ្ញត្តិដែលមានចែងដូចខាងក្រោមនេះ :

a-មានទីលំនៅសមរម្យ

b-ការផ្តល់យោបល់ និងពត៌មានក្នុងករណីចាំបាច់នៃសិទ្ធិស្របច្បាប់របស់ពួកគេក្នុងភាសាមួយដែលជនរងគ្រោះដោយអំពើជួញដូរអាចយល់បាន ។

c-ជំនួយទាំងផ្នែកវេជ្ជសាស្ត្រ ហើយនិងផ្នែកសំភារៈ ហើយនិង

d-ផ្តល់នូវឱកាសអោយមានការធ្វើការងារ ការសិក្សា និងការបណ្តុះបណ្តាល

៤-រដ្ឋនីមួយៗជាសមាជិកត្រូវទទួលខុសត្រូវក្នុងការអនុវត្តបញ្ញត្តិនៃមាត្រានេះ អាយុ ភេទ និងសេចក្តីត្រូវការជាចាំបាច់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សខុសច្បាប់ ជាពិសេសតម្រូវការចាំបាច់របស់កុមារដោយរាប់បញ្ចូលទាំងការស្នាក់នៅដ៏សមរម្យ ការអប់រំ និងការថែទាំ ។

៥-រដ្ឋនីមួយៗដែលជាសមាជិកត្រូវខិតខំខ្នះខ្នែង ដើម្បីផ្តល់អោយនូវសុវត្ថិភាពផ្នែកផ្លូវកាយដល់ជនរងគ្រោះ ក្នុងខណៈដែលពួកគេស្ថិតក្នុងបូរណភាពទឹកដីរបស់ខ្លួន ។

៦-រដ្ឋនីមួយៗដែលជាសមាជិកត្រូវធានានូវប្រព័ន្ធច្បាប់ប្រទេសរបស់ខ្លួននូវវិធានការ ដែលផ្តល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅតាមលទ្ធភាពដែលអាចទទួលបាននូវប្រាក់សំណងចំពោះការខូចខាតពីការឈឺចាប់នេះ ។

## មាត្រា ៧

## ស្ថានភាពរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងរដ្ឋជាម្ចាស់ផ្ទះ

១-លើសពីនេះទៅទៀតដើម្បីចាត់នូវវិធានការដែលទាក់ទិនទៅនឹងមាត្រាទី ៦ នៃពិធីសារនេះ រដ្ឋនីមួយៗជាសមាជិកត្រូវពិចារណាពីការអនុម័តច្បាប់ ឬក៏វិធានការសមស្របដែលអនុញ្ញាតអោយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតែនៅជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ នៅក្នុងបូរណភាពដែនដីរបស់ខ្លួនទៅតាមករណីសមស្រប ។

២-ក្នុងការអនុវត្តនីនូវបទបញ្ញត្តិដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះរដ្ឋនីមួយៗជាសមាជិកត្រូវផ្តល់នូវការពិចារណាអោយសមស្របចំពោះកិច្ចការមនុស្សធម៌ និងក្តីមេត្តាអាណិតអាសូរ ។

## មាត្រា ៨

## ការធ្វើមាតុភូមិនិវត្តន៍នៃជនរងគ្រោះដោយអំពើជួញដូរ

១-រដ្ឋដែលជាសមាជិកនៃជនរងគ្រោះដោយអំពើជួញដូរមនុស្សមានសញ្ជាតិរបស់ខ្លួន ឬក៏ជាមនុស្សដែលមានសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍ នៅពេលដែលចូលទៅក្នុងបូរណភាពទឹកដីរបស់រដ្ឋជាម្ចាស់ផ្ទះ ដែលជាសមាជិកត្រូវផ្តល់ភាពងាយស្រួលនឹងទទួលដោយធានានូវសុវត្ថិភាពដល់ជននោះ ហើយអោយការវិលត្រឡប់ជននោះដោយគ្មានពន្យាពេលអោយជ្រុលហួសហេតុ ឬក៏មិនសមហេតុផល ។

២-នៅពេលដែលរដ្ឋមួយជាសមាជិក បញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រឡប់ទៅអោយរដ្ឋជាម្ចាស់ដើមវិញដែលជាសមាជិកមួយទៀតដែលជនរងគ្រោះនោះ តាមសញ្ជាតិដែលគេមាន នៅពេលដែលចូលទៅក្នុងបូរណភាពទឹកដីនៃរដ្ឋជាម្ចាស់ផ្ទះ សិទ្ធិនៃការស្នាក់នៅជាអចិន្ត្រៃយ៍ ត្រូវបានធានាសុវត្ថិភាពនៃការវិលត្រឡប់មកវិញរបស់ជននោះ ហើយនិងចំពោះទម្រង់ការច្បាប់ផ្សេងៗដែលពាក់ព័ន្ធទៅនឹងអង្គហេតុពិតនៃជននោះ
គឺពិតជាជាជនរងគ្រោះដោយអំពើជួញដូរ ហើយពេញចិត្តដោយធ្វើការវិលត្រឡប់វិញ។

៣-សេចក្តីស្នើសុំរបស់រដ្ឋដែលជាម្ចាស់ផ្ទះបានធ្វើសំណូមពរដល់រដ្ឋជាសមាជិកមួយទៀត នឹងមិនត្រូវធ្វើការពន្យាពេលអោយជ្រុលហួសហេតុ ឬក៏មិនសមហេតុផល បញ្ជាក់ថាជនដែលរងគ្រោះដោយអំពើជួញដូរមានសញ្ជាតិរបស់ខ្លួន ឬក៏មានសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងបូរណភាពទឹកដីរបស់ខ្លួន នៅមុនពេលដែលចូលមកក្នុងបូរណភាពទឹកដីរបស់រដ្ឋជាម្ចាស់ផ្ទះ។

៤-ដើម្បីផ្តល់ភាពងាយស្រួលដល់ការវិលត្រឡប់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សខុសច្បាប់ ដែលពួកគេគ្មានឯកសារត្រឹមត្រូវរដ្ឋជាសមាជិកដែលជនរងគ្រោះមានសញ្ជាតិខ្លួននោះគេមានសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍នៅពេលដែលចូលក្នុងដែនដីនៃការគ្រប់គ្រងរបស់រដ្ឋជាម្ចាស់ផ្ទះនិងយល់ព្រមចេញអោយប្រើប្រាស់ទៅតាមសំណូមពររបស់រដ្ឋជាម្ចាស់ផ្ទះដូចជាឯកសារទាំងឡាយ តាមសំណើរបស់រដ្ឋជាម្ចាស់ផ្ទះ ឬការផ្តល់សិទ្ធិផ្សេងទៀតដែលចាំបាច់អោយជននោះវិលត្រឡប់ទៅកន្លែងដើមរបស់គេវិញ ។

៥-មាត្រានេះនឹងគ្មានអ្វីដែលធ្វើអោយប៉ះពាល់ដល់ការផ្តល់សិទ្ធិណាមួយចំពោះជនរងគ្រោះដោយអំពើនៃការជួញដូរមនុស្សតាមច្បាប់របស់ប្រទេសណាមួយនៃរដ្ឋដែលជាម្ចាស់ផ្ទះ ។

៦-មាត្រានេះមិនគ្មានអ្វីដែលធ្វើអោយប៉ះពាល់ដល់ការអនុវត្តន៍នៃកិច្ចព្រមព្រៀងណាមួយជាទ្វេភាគី ឬពហុភាគី ឬក៏ការចាត់ចែងដោយគ្រប់គ្រងទាំងមូល ឬផ្នែកខ្លះនៃការវិលត្រឡប់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## III-ការការពារ កិច្ចសហប្រតិបត្តិការនិងវិធានការផ្សេងៗ

### មាត្រា ៩

### ការការពារជនរងគ្រោះដោយអំពើជួញដូរ

១-បណ្តារដ្ឋដែលជាសមាជិកត្រូវបង្កើតនូវកិច្ចការពារការជួញដូរមនុស្ស គោលនយោបាយ និងវិធានការផ្សេងៗ អោយបានទូលំទូលាយ :

a-ទប់ស្កាត់ ហើយនិងប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្ស និង

b-ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ពីការធ្វើអោយគេរងគ្រោះឡើងវិញ ។

២-បណ្តារដ្ឋដែលជាសមាជិកត្រូវខិតខំខ្នះខ្នែង ដើម្បីទទួលខុសត្រូវនូវបណ្តាវិធានការទាំងឡាយដូចជា ធ្វើការស្រាវជ្រាវពត៌មាន ហើយនិងយុទ្ធនាការផ្សព្វផ្សាយតាមរយៈធាតុអាកាសគ្រប់ទិសទីក្នុងសង្គមព្រមទាំងធ្វើការផ្តួចផ្តើមផ្នែកសេដ្ឋកិច្ចជាលើកដំបូង ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។

៣-រាល់កម្មវិធីនយោបាយ និងបណ្តាវិធានការផ្សេងៗទៀត ដែលត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមមាត្រានេះ អោយបានសមស្របដោយរាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល ឬក៏អង្គការដទៃទៀតដែលពាក់ព័ន្ធព្រមទាំងសមាសភាពសង្គមស៊ីវិលផ្សេងៗទៀត ។

៤-បណ្តារដ្ឋដែលជាសមាជិកត្រូវចាត់ ឬពង្រឹងនូវបណ្តាវិធានការដោយរាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី ដើម្បីជួយសម្រួលដល់កត្តាដែលធ្វើអោយមនុស្ស ជាពិសេសស្ត្រី និងកុមារដែលងាយរងនូវឈឺចាប់ដោយអំពើជួញដូរ ដូចជាភាពក្រីក្រ ការមិនទាន់មានភាពរីកចម្រើនពេញលេញ និងគ្មាននូវឱកាសស្មើភាពគ្នា ។

៥-បណ្តារដ្ឋដែលជាសមាជិកត្រូវអនុម័ត និងពង្រឹងនីតិបញ្ញត្តិ ឬបណ្តាវិធានការផ្សេងៗ ដូចជាវិធានការលើការអប់រំសង្គម ឬក៏ផ្នែកវប្បធម៌ដោយរាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី ដើម្បីរារាំងពីតម្រូវការដែលជម្រុញអោយមានការទាញយកផលប្រយោជន៍ពីមនុស្សជាច្រើនទម្រង់ ជាពិសេសស្ត្រី និងកុមារដែលនាំមុខគេក្នុងអំពើជួញដូរ ។

### មាត្រា ១០

### ការផ្លាស់ប្តូរពត៌មាន និងការបណ្តុះបណ្តាល

១-ការអនុវត្តន៍ច្បាប់ផ្នែកអន្តោប្រវេសន៍ ឬអាជ្ញាធរដទៃទៀតដែលពាក់ព័ន្ធនៃបណ្តារដ្ឋជាសមាជិក ចាំបាច់ត្រូវធ្វើកិច្ចសហប្រតិបត្តិការអោយបានសមស្របជាមួយអាជ្ញាធរផ្សេងទៀត តាមការផ្លាស់ប្តូរពត៌មានដោយអនុលោមទៅតាមច្បាប់ប្រទេសរបស់គេ ដើម្បីអោយពួកគេធ្វើការសម្រេចចិត្ត :

a-ប្រសិនបើបុគ្គលម្នាក់ធ្វើការឆ្លងកាត់ ឬមានបំណងឆ្លងកាត់ព្រំដែនអន្តរជាតិដោយប្រើប្រាស់ឯកសារធ្វើដំណើរដែលជាកម្មសិទ្ធរបស់អ្នកដទៃ ឬក៏គ្មានឯកសារធ្វើដំណើរ ជាអ្នកប្រព្រឹត្តនូវបទឧក្រិដ្ឋ ឬជនរងគ្រោះដោយអំពើជួញដូរខុសច្បាប់ ។

b-រាល់ប្រភេទនៃឯកសារធ្វើដំណើរដែលបុគ្គលម្នាក់ៗបានប្រើប្រាស់ ឬមានបំណងនឹងប្រើប្រាស់ដើម្បីឆ្លងកាត់ព្រំដែនអន្តរជាតិ ក្នុងគោលបំណងជួញដូរមនុស្សខុសច្បាប់ និង

c- រាល់មធ្យោបាយ និងវិធីដែលបានប្រើប្រាស់ដោយក្រុមឧក្រិដ្ឋជនដែលបានចាត់តាំងឡើង ក្នុងគោលបំណងជួញដូរមនុស្ស ដោយរួមមានទាំងការជ្រើសរើសសមាជិកថ្មី ការដឹកជញ្ជូនជនរងគ្រោះតាមផ្លូវ ព្រមទាំងទាក់ទិនទៅនឹងក្រុមមនុស្សដែលពាក់ព័ន្ធ ក្នុងករណីជួញដូរមនុស្ស ត្រូវចាត់វិធានការទៅតាមលទ្ធភាព ដើម្បីស្រាវជ្រាវរកជនទាំងនោះ ។

២-បណ្តារដ្ឋដែលជាសមាជិកត្រូវផ្តល់អោយ ឬក៏ពង្រីកការបណ្តុះបណ្តាលសម្រាប់អនុវត្តច្បាប់ផ្នែកអន្តោប្រវេសន៍ និងបណ្តាមន្ត្រីដែលពាក់ព័ន្ធដទៃទៀតក្នុងកិច្ចការពារនូវអំពើជួញដូរមនុស្សខុសច្បាប់ ។ វគ្គបណ្តុះបណ្តាលនឹងត្រូវផ្តោតទៅលើរបៀបនៃការប្រើប្រាស់ក្នុងកិច្ចការពារនូវអំពើជួញដូរមនុស្ស កាត់ទោសចំពោះអ្នកទាំងឡាយណាដែលជួញដូរមនុស្ស ហើយនិងការការពារសិទ្ធិរបស់ជនរងគ្រោះរួមមានទាំងកិច្ចការពារជនរងគ្រោះពីអ្នកជួញដូរមនុស្សខុសច្បាប់ ។ វគ្គបណ្តុះ-បណ្តាលក៏នឹងមានការចាំបាច់ទទួលខុសត្រូវផងដែរ ដោយពិចារណាទៅលើសិទ្ធិមនុស្ស ហើយនិងកុមារ បញ្ហាស្រើបស្រាលផ្លូវភេទ ហើយនិងជម្រុញអោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល និងអង្គការដែលពាក់ព័ន្ធទៅនឹងសង្គមស៊ីវិលដទៃទៀត ។

៣-រដ្ឋមួយដែលជាសមាជិកទទួលបាននូវពត៌មាន នឹងត្រូវធ្វើទៅតាមសេចក្តីស្នើសុំដោយរដ្ឋមួយដែលជាសមាជិកដែលបានបញ្ជូនពត៌មានទៅតាមទីកន្លែងជាក់លាក់ស្តីពីការប្រើប្រាស់របស់ខ្លួន។

## មាត្រា ១១
## វិធានការព្រំដែន

១-ដោយមិនប្រកាន់ពូជសាសន៍ក្នុងការប្តេជ្ញាចិត្តជាអន្តរជាតិ ក្នុងទំនាក់ទំនងចលនាសេរីភាពមនុស្សរដ្ឋជាសមាជិកនឹងត្រូវពង្រឹងអោយអស់លទ្ធភាពដូចជា ករណីត្រួតពិនិត្យព្រំដែនដែលអាចនឹងមានការចាំបាច់ ដើម្បីការពារ និងរកអោយឃើញអំពើជួញដូរមនុស្សខុសច្បាប់ ។

២-បណ្តារដ្ឋជាសមាជិកនីមួយៗ នឹងត្រូវអនុម័តច្បាប់ ឬវិធានការដ៏ប្រសើរដើម្បីការពារអោយអស់លទ្ធភាពមធ្យោបាយដឹកជញ្ជូនដោយអាជីពពាណិជ្ជកម្ម ការប្រើប្រាស់នៅក្នុងបេសកកម្មនៃបទល្មើសដែលបង្កើតឡើងអនុលោមទៅតាមមាត្រាទី ៥ នៃពិធីសារនេះ ។

៣-គ្រប់ទីកន្លែងដែលសមស្រប និងគ្មានការប្រកាន់ពូជសាសន៍ដែលអនុវត្តបានទៅតាមអនុសញ្ញាអន្តរជាតិ វិធានការទាំងនេះរួមមាន ការបង្កើតនូវកាតព្វកិច្ច នៃអាជីពពាណិជ្ជកម្ម ក្នុងនោះមានក្រុមហ៊ុនដឹកជញ្ជូនផ្សេងៗ ឬម្ចាស់ក្រុមហ៊ុន ឬជាអ្នកអនុវត្តនូវមធ្យោបាយនៃការដឹកជញ្ជូននានា រកអោយឃើញប្រាកដថាអ្នកធ្វើដំណើរទាំងនោះ តម្រូវអោយមានឯកសារផ្ទាល់ខ្លួនក្នុងការចូលទៅរដ្ឋជាម្ចាស់ផ្ទះ ។

៤- បណ្តារដ្ឋជាសមាជិកនីមួយៗត្រូវអនុវត្តវិធានការចាំបាច់អនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន ដើម្បីផ្តល់ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ក្នុងករណីមានការរំលោភលើកាតព្វកិច្ចដែលបានចែងក្នុងវគ្គ ៣ នៃមាត្រានេះ ។

៥- បណ្តារដ្ឋជាសមាជិកត្រូវធ្វើការពិចារណា អនុវត្តនូវវិធានការដែលបានអនុញ្ញាត យោងទៅតាមច្បាប់របស់ខ្លួន ការបដិសេធមិនអោយចូល ឬការលុបចោលទិដ្ឋាការរបស់អ្នកស្នើសុំ ក្នុងបេសកកម្មនៃបទល្មើសដែលបង្កើតឡើងយោងតាមពិធីសារនេះ ។

៦-យោងតាមមាត្រាទី ៧ នៃអនុសញ្ញានេះដោយមិនប្រកាន់ពូជសាសន៍ រដ្ឋជាសមាជិកនីមួយៗ នឹងត្រូវពិចារណាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារត្រួតពិនិត្យព្រំដែន នៅក្នុងនោះដោយមានការបង្កើត និងរក្សានូវទំនាក់ទំនងផ្ទាល់ ។

## មាត្រា ១២
## ការត្រួតពិនិត្យឯកសារ និងសន្តិសុខ

បណ្តារដ្ឋជាសមាជិកនីមួយៗ ត្រូវអនុវត្តវិធានការទាំងនេះក្នុងករណីចាំបាច់ជាមួយមធ្យោបាយដែលមាន